## លទ្ធផលនៃជម្ងឺ កូវីដ មានភាពស្រកចុះ ... គម្រោងបើកសាលារៀននៅតែបន្តធ្វើ

ជម្រាបជូនសហគមន៍សាលារៀន ឡុងប៊ីច

នៅពេលលទ្ធផលនៃជម្ងឺ កូវីដ-១៩ ទទួលការស្រកចុះនៅតាម ឡូស អ៊ែនជេឡេស ខោនធី គឺក្រសួងអប់រំ ឌីស្រ្ទីគ ឡុងប៊ីច បន្តធ្វើការរៀបជាគម្រោងសម្រាប់បញ្ជូនសិស្សបន្តិចម្តងៗអោយត្រឡប់ចូលរៀននៅតាមថ្នាក់វិញ ។

លទ្ធផលកែប្រែនៃជម្ងឺ កូវីដ ក្នុងសប្តាហ៍នេះនៅតាម ឡូស អ៊ែនជេឡេស ខោនធី គឺមានកម្រិតឆ្លងជា 31.7 ក្នុងចំណោមមនុស្ស 100,000 នាក់ ដែលបង្ហាញភាពស្រកចុះច្រើនណាស់ បើប្រៀបធៀបទៅជាមួយពេល បី សប្តាហ៍កន្លងមក ដែលនៅពេលនោះ គឺមានកម្រិតឆ្លងជា 100 ក្នុងចំណោមមនុស្ស 100,000 នាក់ ។ មានការចែកផ្តល់ជាបន្ថែមអំពីការចាក់ថ្នាំ វ៉ាក់ស៊ីន លើកដំបូងទៅកាន់គ្រូបង្រៀនចំនួន 400 នាក់នៅក្នុងសប្តាហ៍នេះ ដែលបូកទាំងអស់ទៅមានចំនួនប្រហែល 2,000 នាក់ជាគ្រូបង្រៀន និង បុគ្គលិកផ្សេងៗប្រចាំក្រសួងអប់រំ LBUSD ដែលបានណាត់ពេលជួបផ្ទាល់សម្រាប់ទទួលការចាក់ថ្នាំតាំងពី ថ្ងៃទី25 ខែមករា កន្លងមក ។ សម្រាប់សុខភាពនៅក្នុងសហគមន៍របស់យើង គឺនេះជាពត៏មានមួយដ៏ល្អ ។

នៅពេលជាមួយគ្នានេះ គឺមានការរៀបចំកម្មវិធីហ្វឹកហ្វឺនជាបន្ថែមស្តីអំពីសុខភាព និង សុវត្ថិភាពសម្រាប់ផ្តល់ទៅកាន់នាយកដឹកនាំសាលារៀន ។ ទូទាំងខែកុម្ភៈ ក្រសួងអប់រំ ឌីស្រ្ទីគ នឹងធ្វើបន្តអំពីការរាយផ្សាយពត៌មានថ្មីៗ ដែលរាប់បញ្ចូលទាំងការចាក់ វិដេអូ ផងសម្រាប់បង្ហាញការរៀបចំនៅតាមថ្នាក់រៀនជាលក្ខណៈបំបែកដាច់ពីគ្នា និង អ្វីផ្សេងៗទៀតសម្រាប់ការពារសុខភាព ។ បើកមើលគំរូនៅទីនេះ ។

កាលពីថ្ងៃទី14 ខែធ្នូ កន្លងមក ក្រសួងអប់រំ LBUSD បានប្រកាសជាសាធារណៈអំពីថ្ងៃខែត្រូវប្រើសម្រាប់បើកសាលារៀនឡើងវិញ ដោយសំអាងលើកម្រិតស្រកចុះពីលទ្ធផលនៃជម្ងឺ កូវីដ នៅក្នុងសហគមន៍ ។ សេចក្តីសង្ឃឹម គឺចាប់ផ្តើមបើកសាលារៀនឡើងវិញជាបន្តិចម្តងៗសម្រាប់ទទួលសិស្សថ្នាក់បឋមសិក្សានៅថ្ងៃទី1 ខែមិនា និង ថ្ងៃទី12 ខែមេសា ជាថ្ងៃខែប្រើជំនួស បើចាំបាច់ ដោយយោងស្របតាមលទ្ធផលទាក់ទងផ្នែកសុខភាព ។ តាំងពីថ្ងៃទី14 ខែមករា កន្លងមក ក្រសួងសុខាភិបាលប្រចាំរដ្ឋ កាលីហ្វ័រញ៉ា បានធ្វើការកែប្រែក្បួនណែនាំសម្រាប់អាចបើកសាលាបឋមសិក្សាឡើងវិញបាន នៅពេលមានកម្រិតឆ្លងធ្លាក់ក្រោម 25 ក្នុងចំណោមមនុស្ស 100,000 នាក់ ។ បើលទ្ធផលទាក់ទងផ្នែកសុខភាពសព្វថ្ងៃនេះនៅតែមានជាបន្ត និង បើការចែងតម្រូវមកពី រដ្ឋ គ្មានអ្វីកែប្រែ គឺសាលាបឋមសិក្សានឹងអាចបើកទ្វារឡើងវិញបានក្នុងពេលឆាប់ៗនេះនៅតាម ឡូស អ៊ែនជេឡេស ខោនធី ។

ក្នុងកិច្ចប្រជុំគណៈកម្មការនាយកផ្នែកសិក្សាធិការនៅថ្ងៃទី17 ខែកុម្ភៈ គឺបុគ្គលិកសាលារៀននឹងលើកបង្ហាញជាអនុសាសន៍សម្រាប់ការបើកសាលារៀនបន្តិចម្តងៗឡើងវិញ ។

**តើសិស្សនៅតាមកម្រិតថ្នាក់ទាំងអស់នឹងត្រឡប់ចូលរៀនវិញក្នុងពេលជាមួយគ្នា មែនទេ?**
មិនមែនទេ ។ ដោយមូលហេតុថា ការប្រើច្បាប់ចែងតម្រូវនៅតាមសាលាបឋមសិក្សា និង សាលាកម្រិតថ្នាក់ខ្ពស់សម្រាប់ទទួលសិស្សចូលរៀនវិញមានភាពខុសពីគ្នា គឺក្រសួងអប់រំ ឌីស្រ្ទីគ មានគម្រោងបើកសាលាបឋមសិក្សាជាមុនសិន ហើយនៅពេលលទ្ធផលនៃជម្ងឺកាន់តែស្រកចុះ គឺយើងនឹងបើកសាលាឡើងវិញសម្រាប់ទទួលសិស្សរៀនកម្រិតថ្នាក់ខ្ពស់ - មធ្យមសិក្សា និង វិទ្យាល័យ ។

**តើសិស្សនឹងចូលរៀនពេញថ្ងៃ មែនទេ បើក្រុមគ្រួសារជ្រើសរើសយកការបង្ហាត់នៅតាមថ្នាក់?**
មិនមែនទេ ។ ចំពោះសិស្សរៀនកម្រិតថ្នាក់បឋមសិក្សា ដែលក្រុមគ្រួសាររបស់ខ្លួនបានជ្រើសរើសយកការបង្ហាត់នៅតាមថ្នាក់ គឺពួកគេនឹងចំណាយពេលរៀនចំនួន 2.5 ម៉ោងក្នុងមួយថ្ងៃ ។ ពេលនៅសល់ទាំងប៉ុន្មាន គឺនឹងចំណាយនៅតាមផ្ទះ ឬ កន្លែងទទួលផ្ញើក្មេងសម្រាប់បំពេញកិច្ចការប្រចាំថ្ងៃ ដែលគ្រូបង្រៀនដាក់អោយធ្វើតាម ។

**តើនឹងមានការចែងតម្រូវអោយគ្រូបង្រៀន និង សិស្សទទួលការចាក់ថ្នាំ មែនទេ នៅពេលត្រឡប់ចូលរៀនឡើងវិញ?**
គ្មានការចែងតម្រូវអ្វីទេសម្រាប់អោយបុគ្គលិកទទួលការចាក់ថ្នាំ មុននឹងដល់ពេលត្រឡប់ធ្វើការនៅតាមសាលារៀនឡើងវិញ ។ ប៉ុន្តែ ក្រសួងអប់រំ LBUSD នៅតែបន្តសហការណ៍ជាមួយក្រសួងសុខាភិបាល ឡុងប៊ីច ដើម្បីផ្តល់ជាការចាក់ថ្នាំទៅកាន់បុគ្គលិកទាំងអស់ ដែលមានបំណងទទួលការចាក់ថ្នាំ ។ គ្មានការទទួលយល់ព្រមអ្វីទេមកលើការចាក់ថ្នាំសម្រាប់សិស្ស ម្លោះហើយ គឺគ្មានការចែងតម្រូវមកពីរដ្ឋ ទាល់តែសោះសម្រាប់ទាមទារអោយសិស្សចាក់ថ្នាំ ។

**តើបុគ្គលិកសាលារៀន និង សិស្សនឹងត្រូវបានទទួលការចែងតម្រូវ មែនទេ សម្រាប់ធ្វើ តែស្ត កូវីដ នៅពេលសាលារៀនបើកឡើងវិញ?**
បើ ឡូស អ៊ែនជេឡេស ខោនធី នៅតែស្ថិតក្នុងជាន់ថ្នាក់ជាពណ៌ ស្វាយ (purple tier) ឬ ជាន់ថ្នាក់ជាកម្រិតតឹងបំផុត (Tier I) គឺបុគ្គលិក និង សិស្សទាំងអស់ ដែលត្រឡប់ចូលសាលារៀនឡើងវិញ នឹងត្រូវបានទទួលការចែងតម្រូវប្រចាំសប្តាហ៍អោយធ្វើ តែស្ត តាមរយៈត្បារច្រមុះ និង ពិនិត្យសញ្ញារោគផ្សេងៗ ដែលមិនបង្ហាញ នៅតាមសាលារៀន ។ នេះមានន័យថា ថ្វីត្បិតតែសិស្ស និង បុគ្គលិកមិនបង្ហាញសញ្ញារោគ កូវីដ ជាពិតមែន ក៏ពួកគេនៅតែទទួលការធ្វើ តែស្ត សម្រាប់ជាគម្រោងការពារបន្ថែមមកលើសុវត្ថិភាព ។ Anterior nasal គឺសំដៅមកលើផ្នែកខាងមុខនៃច្រមុះ ។ ការត្បារច្រមុះរបៀបនេះមិនសូវជាពិបាកធ្វើដូចការធ្វើ តែស្ត ម្យ៉ាងផ្សេងទៀត ដែលរុកចូលកាន់តែជ្រៅដល់ពាក់កណ្តាល ឬ ផ្នែកខាងក្រោយនៃច្រមុះ ។ បន្ទាប់ពី ឡូស អ៊ែនជេឡេស ខោនធី ធ្លាក់ចុះទៅកាន់ជាន់ថ្នាក់មានភាពកាន់តែធូរទៅ គឺការពិនិត្យសញ្ញារោគផ្សេងៗ ដែលមិនបង្ហាញ ប្រហែលជានឹងបន្ថយធ្វើ ឬ ឈប់ធ្វើជាបន្តទៅទៀត ។ ការរៀបរាប់កាន់តែច្បាស់ទាក់ទងមកលើប្រភេទនៃការធ្វើ តែស្ត និង ការចាត់ចែងធ្វើ តែស្ត គឺនឹងមានផ្តល់ជូននៅពេលណាបានទទួល ។

សូមអរគុណចំពោះជំនួយគាំទ្រជាបន្តបន្ទាប់ពីលោកអ្នកសម្រាប់សិស្ស និង សាលារៀនរបស់យើង ។

ដោយសេចក្តីកក់ក្តៅ,

Jill

Jill Baker, Ed. D.
អគ្គនាយកសាលារៀន